01136665

002/19-09-2007-ECCC/TC
E1/324

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 09 / 2015
ម៉ោង (Time/Heure): 09:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ អង្គារ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

**សវនាការលើអង្គសេចក្ដី - ថ្ងៃ ៣០៥**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Maddalena GHEZZI**

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន) , ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Mar LAVERGNE, ចៅក្រម Martin KAROPKIN, ចៅក្រម យូរ ឧត្ដារា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Travis FARR, លោក Joseph ANDREW BOYLE, លោក សេង លាង, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក |

| |
|---|
| ហុង គឹមសួន, លោក វ៉ែន ពៅ, លោកស្រី ទី ស្រីនណា, លោកស្រី ស៊ីន សុវ៉ន |
| សាក្សី/ដើមបណ្ដឹង៖ សែន សុផុន (2-TCCP-220), ម៉ម សឿម (2-TCW-858) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោកស្រី សំ មករា, លោកស្រី ពេជ ចរិយា, កញ្ញា ស្រី ណាក់, កញ្ញា សុក សុភ័គមណីកា, លោក លី សុតុល្យ, កញ្ញា Joëlle TRAMPERT, កញ្ញា Clémentine PLAGNOL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៦.០៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖ ១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.១៧ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១៣ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០១ | ០៩.០៤ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៤ | ០៩.០៦ |
| សំណើរបស់មេធាវីការពារក្តី នួន ជា សុំការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងឯកសារមួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនទាន់មានការបកប្រែទៅជាភាសាអង់គ្លេស និង ភាសាបារាំង | មេធាវីការពារក្តី នួន ជា<br><br><br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br><br><br><br>សហមេធាវីនាំមុខ | ០៩.០៦<br>១៥.០២<br>១៦.០៤<br>០៩.១៦<br>០៩.១៧<br>១០.០៩<br>១៥.០៥<br>១៦.០២<br>០៩.១៩ | ០៩.១៥<br>១៥.០៤<br>១៦.០៤<br>០៩.១៧<br>០៩.២០<br>១០.១៣<br>១៥.០៥<br>១៦.០២<br>០៩.១៩ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្តី ខៀវ សំផន | ១៦.០៤ | ១៦.០៥ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន (2-TCCP-220) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>ដើមបណ្តឹងរដ្ឋប្បវេណី | ០៩.២២<br>១០.៣១<br>១១.០៨ | ១០.០៩<br>១១.០៧<br>១១.១៥ |
| ការតាំងសំណួរទៅសាក្សី ម៉ម សឿម (2-TCW-858) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ១៣.៣៦<br>១៣.៤៩<br>១៥.៣៤ | ១៣.៤៩<br>១៥.៣៤<br>១៦.០២ |
| ការជំទាស់របស់មេធាវីការពារក្តី នួន ជា ទៅនឹងការតាំងសំណួររបស់សហព្រះរាជអាជ្ញា ដោយគិតទៅដល់សេចក្តីសម្រេចរបស់តុលាការកំពូល F26 | មេធាវីការពារក្តី នួន ជា<br><br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ | ១៤.១៨<br>១៤.២៤<br>១៤.១៩<br>១៤.២០<br>១៤.២៥<br>១៤.៣០ | ១៤.១៩<br>១៤.២៥<br>១៤.២០<br>១៤.២៤<br>១៤.២៧<br>១៤.៣២ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>សំណើររបស់មេធាវីការពារក្តី នួន ជា សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឯកសារមួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមិនទាន់មានការបកប្រែទៅជាភាសាអង់គ្លេស និងភាសាបារាំង</u>**

មេធាវីការពារក្តី នួន ជា បានលើកឡើងទាក់ទងនឹងការប្រើប្រាស់ឯកសារ ទាំង ៦៦ ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលសេចក្តីសង្ខេបនៃឯកសារទាំងនោះត្រូវបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញានៅក្នុងសវនាការបច្ចុប្បន្ន (E353)។ មេធាវីការពារក្តី នួន ជា បានកត់សម្គាល់ថា ឯកសារទាំង ៦៦ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានតែ ១៣ ឯកសារប៉ុណ្ណោះ ដែលរួមទាំងឯកសារមួយដែលពួកគេមានបំណងប្រើប្រាស់ (E3/8991) បានបកប្រែទៅជាភាសាអង់គ្លេស និងមិនមានជាភាសាបារាំងនោះទេ។

អង្គជំនុំជម្រះ បានស្នើឱ្យមេធាវីការពារក្ដី នួន ជា ផ្ដល់នូវបញ្ជីឯកសារទាំង ៦៦ ទៅអង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះអាចពិចារណាទៅលើបញ្ហាទាំងនេះ។

**ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន (2-TCCP-220)**

មេធាវីការពារក្ដី នួន ជា និង ខៀវ សំផន បានតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន (2-TCCP-220)។ ជាចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មដែលខ្លួនបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ការតាំងសំណួរទៅសាក្សី ម៉ម សឿម (2-TCW-858)**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សី ព្រមទាំងប្រាប់អំពីសិទ្ធិ និងករណីកិច្ចទៅសាក្សី ម៉ម សឿម (2-TCW-858)។ បន្ទាប់មក សហព្រះរាជអាជ្ញា សហមេធាវីនាំមុខបានធ្វើការតាំងសំណួរជាបន្ត។

**ការជំទាស់របស់មេធាវីការពារក្ដី នួន ជា ទៅនឹងការតាំងសំណួររបស់សហព្រះរាជអាជ្ញា ដោយគិតទៅដល់សេចក្ដីសម្រេចរបស់តុលាការកំពូល F26**

មេធាវីការពារក្ដី នួន ជា បានជំទាស់ទៅនឹងលក្ខណៈនៃការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា ដែលបានដកស្រង់សេចក្ដីថ្លែងការណ៍មុនៗរបស់សាក្សី និងស្នើសុំការបញ្ជាក់ពីសាក្សី។ ភាគីផ្សេងទៀតបានបង្ហាញពីមតិយោបល់របស់ខ្លួនទៅលើការជំទាស់នេះ។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឱ្យភាគីសួរសំណួរបើក ហើយអាចសួរបញ្ជាក់នៅក្នុងករណីដែលចម្លើយរបស់សាក្សីមានភាពផ្ទុយគ្នាពីការផ្ដល់សក្ខីកម្មលើកមុន ទើបសំណួរបន្តបន្ទាប់មកទៀត ភាគីអាចដកស្រង់នូវកំណត់ហេតុដែលគាត់បានឆ្លើយលើកមុនមកបញ្ជាក់ពីបញ្ហានេះ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្ដុតាង**

New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9440 | D22/1232/1 | N/A; 00523258-00523259; N/A | Victim Unit's Report on Civil Party Applicant SEN Sophon 09-VU-00979 | P | N/A | 00523259 | N/A |

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/8991 | E305/13.23.292 | 00730216-00730242; 00969882-00969917; N/A | Statement of BOU Mao (DC-Cam) | P | 00730232 | 00969903 | N/A |
| E3/8050 | D232/96 | 00464718-00464724; 00428004-00428008; 00450433-00450437 | Report of the Execution of Rogatory Letter, dated 06-01-2010: Site Identification Report | P | 00464719 | 00428005 | 00450434 |
| E3/7323 | D166/99 | 00279086-00279091; 00289997-00290002; 00483957-00483962 | Written Record of Interview of HĒNG Samuot | P | 00279088 | 00289999 | 00483959 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4821 | D22/1232 | 00523260-00523269; 00916889-00916892; 00909831-00909836 | Civil party application of SEN Sophon 09-VU-00979 | P | 00523264 | 00916890 | 00909834 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៦)
- ណែនាំឱ្យភាគីតាំងសំណួរបើកជាមុនសិន និងចៀសវាងការអាននូវកំណត់ហេតុមុនៗរបស់សាក្សី លុះត្រាតែចម្លើយរបស់សាក្សីមានភាពផ្ទុយគ្នា។ (១៤.៣០)

- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥។ (១៦.០៧)

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

ក្រឡាបញ្ជី

ផ.ជា ស៊ីទហ៊ិខ

ក្រឡាបញ្ជី

Maddalena GHEZZI